THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Tony B. Watlington Sr., Ed.D.**
Superintendent

ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២៤

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

**សិស្សថ្នាក់ទី ៣ ដល់ ទី ៨ នឹងចូលរួមក្នុង ការប្រឡងតាមប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេនញ៉ា (PSSA) រវាងថ្ងៃទី ២២ ខែ មេសា ដល់ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០២៤។**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ត្រូវបានដឹកនាំដោយ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និងល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឱ្យសិស្សមានជោគជ័យ Goals & Guardrails របស់ក្រុមប្រឹក្សាភិបាលអប់រំ។ គោលដៅរបស់ក្រុមប្រឹក្សាភិបាលគឺចង់ឃើញសិស្សគ្រប់រូបរៀនបានលើ ឬតាមកម្រិតថ្នាក់ ក្នុងមុខវិជ្ជាសំខាន់ៗ ហើយបញ្ចប់ការសិក្សាត្រៀមខ្លួនសម្រាប់មហាវិទ្យាល័យ និងអាជីព។ PSSA គឺជាឧបករណ៍ដ៏សំខាន់ដែលអនុញ្ញាតឱ្យឪពុកម្ដាយ អាណាព្យាបាល និងអ្នកអប់រំ តាមដានការរីកចម្រើនរបស់យើងឱ្យត្រូវតាមគោលដៅទាំងនោះ។ ពិន្ទុរបស់សិស្សជួយគ្រូតាមដានការរីកចម្រើននៃការសិក្សា និងកំណត់ចំណុចខ្លាំង និងតម្រូវការរបស់ក្មេង ដើម្បីឱ្យពួកគេអាចគាំទ្រដល់ការរៀនសូត្ររបស់សិស្សម្នាក់ៗ។ ពិន្ទុ PSSA ក៏ជួយសាលា និងក្រសួងអប់រំបន្តការកែលម្អកម្មវិធីសិក្សា និងការបង្ហាត់បង្រៀនផងដែរ។

**ក្នុងអំឡុងពេលធ្វើតេស្ត PSSA ជាការសំខាន់បំផុតសម្រាប់សិស្សានុសិស្សដែលត្រូវមករៀនជារៀងរាល់ថ្ងៃ។** PSSA ត្រូវបានកំណត់ដោយរដ្ឋ ហើយច្បាប់សហព័ន្ធតម្រូវឱ្យសិស្សទាំងអស់ដែលរៀនថ្នាក់ទី ៣ ដល់ ទី ៨ ចូលរួម។ សាលានីមួយៗត្រូវមានសិស្សយ៉ាងហោចណាស់ចំនួន ៩៥% ប្រឡង ភាសាអង់គ្លេស គណិតវិទ្យា និង វិទ្យាសាស្ត្រ (សម្រាប់ថ្នាក់ទី ៤ និង ទី ៨)។ ប្រសិនបើសាលាមានការចូលរួមក្រោម ៩៥% នោះពិន្ទុនៃការវាយតម្លៃរបស់រដ្ឋសម្រាប់សាលានឹងរងផលប៉ះពាល់អវិជ្ជមាន។

លោកអ្នកអាចស្វែងយល់បន្ថែមអំពី PSSA ដោយប្រើបណ្ដាញតភ្ជាប់ (links) ខាងក្រោមនេះ ឬដោយចូលទៅកាន់ គេហទំព័រ PSSA PSSA website របស់យើង។ សាលារបស់កូនលោកអ្នកក៏នឹងចែករំលែកព័ត៌មាននេះជាមួយលោកអ្នកផងដែរ។

- **PSSA Parent Guide**: ការពិពណ៌នាទូទៅខ្លីៗនៃ PSSA ជាមួយនឹង បណ្ដាញតភ្ជាប់ (links) ទៅកាន់ប្រភពជំនួយសម្រាប់មាតាបិតារបស់ក្រសួងអប់រំ។
- **Frequently Asked Questions**: ទំព័រនៃព័ត៌មានសំខាន់ៗពីក្រសួងអប់រំរដ្ឋ ផិនស៊ីលវេនញ៉ា ដែល

ផ្តល់ចម្លើយចំពោះសំណួរដែលគេឧស្សាហ៍សួរ។

- **PSSA Test Features and Accommodations**: ការពន្យល់អំពីលក្ខណៈពិសេសនៃការប្រឡង និងការជួយសម្របសម្រួលទៅតាមសេចក្តីត្រូវការដែលមានសម្រាប់សិស្ស រួមទាំងបណ្តាញតភ្ជាប់ទៅកាន់ការណែនាំអំពីការជួយសម្របសម្រួលទៅតាមសេចក្តីត្រូវការ។
- **Code of Conduct for Test Takers**: អ្វីដែលគួរធ្វើ និងអ្វីដែលមិនគួរធ្វើ សម្រាប់សិស្សក្នុងអំឡុងពេលធ្វើតេស្ត។

- **Electronic Devices Parent Letter**: លិខិតទៅកាន់ក្រុមគ្រួសាររៀបរាប់លម្អិតអំពីច្បាប់របស់ក្រសួងអប់រំអប់រំរដ្ឋ ផិនស៊ីលវេនញ៉ា និងផលវិបាកនៃការប្រើប្រាស់ទូរស័ព្ទដៃ និងឧបករណ៍អេឡិចត្រូនិកផ្សេងទៀតក្នុងអំឡុងពេលធ្វើតេស្ត។

ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី ការប្រឡងតាមប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេនញ៉ា (PSSA) សូមមើល គេហទំព័រ website របស់ ក្រសួងអប់រំរដ្ឋផិនស៊ីលវេនញ៉ា។ ប្រសិនបើលោកអ្នកមានសំណួរអំពីការវាយតម្លៃរបស់ក្រសួងអប់រំ សូមទាក់ទង ការិយាល័យ វាយតម្លៃ ស្រាវជ្រាវ និងទទួលខុសត្រូវ តាមរយៈនៃការបំពេញលិខិតសម្រាប់ការទាក់ទងរបស់យើង via our contact form។

សូមអរគុណចំពោះការរួមការងារជាមួយក្រសួងអប់រំ ដើម្បីគាំទ្រដល់ការលូតលាស់ និងជោគជ័យរបស់ក្មេងដែលរស់នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ ខណៈពេលដែល PSSA គ្រាន់តែជាមធ្យោបាយមួយដើម្បីវាស់ស្ទង់ការរីកចម្រើន វាផ្តល់នូវព័ត៌មានដ៏សំខាន់បំផុតដែលយើងអាចប្រើប្រាស់ដើម្បីកែលម្អសេវាកម្មរបស់យើងបន្ថែមទៀតដល់ក្មេង និងក្រុមគ្រួសារ ជូនដំណឹងអំពីការអនុវត្តផែនការយុទ្ធសាស្ត្ររបស់យើង និងជួយយើងក្នុងការស្វែងរកចក្ខុវិស័យរបស់យើង ដើម្បីត្រៀមសិស្សទាំងអស់ឱ្យស្រមៃ និងសម្រេចបាននូវអនាគតដែលពួកគេប្រាថ្នា!

ក្នុងភាពជាដៃគូ

Tony

Tony B. Watlington Sr., Ed.D.
អគ្គនាយកនៃក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា